# អនុសាសន៍នៃយន្តការពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកលតាមការកំណត់ (យូ.ភី.អ) អំពីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយកនៅក្នុងជុំទី៣

នៅក្នុង **យន្តការនៃពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកលតាមកាលកំណត់ (យូ.ភី.អ) ជុំទី៣** ឆ្នាំ ២០១៩ **រាជរដ្ឋាភិបាលកម្ពុជាបានទទួលយកអនុសាសន៍ចំនួន៩ ដែលផ្តោតជាពិសេសទៅលើការការពារសិទ្ធិស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ បុគ្គលអន្តរភេទ និងអ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រ។** អនុសាសន៍ដែលបានទទួលយកអំពីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា គឺផ្តោតអាទិភាពចម្បងទៅលើ៣ចំនុចសំខាន់ៗ លើការបង្កើតនិងកែប្រែច្បាប់ និងគោលនយោបាយ៖

- វិសោធនកម្ម មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតឱ្យមានសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា
- បង្កើតឱ្យមានច្បាប់និងគោលនយោបាយស្តីពីការប្រឆាំងនឹងការរើសអើង ឬ បង្កើតឱ្យមានការការពារដល់សហគមន៍អ្នកស្រលាញ់ភេទដូចគ្នា
- បង្កើតឱ្យមានច្បាប់ទទួលស្គាល់អត្តសញ្ញាណយេនឌ័ររបស់អ្នកប្តូរយេនឌ័រ

| អនុសាសន៍នៃយន្តការពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកលតាមការកំណត់ (យូ.ភី.អ) អំពីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយកនៅក្នុងជុំទី៣ | |
|---|---|
| អនុសាសន៍ | ប្រទេសដែលផ្តល់អនុសាសន៍ |
| **វិសោធនកម្មធម្មនុញ្ញ ដើម្បីអនុញ្ញាតឱ្យមានសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា** | |
| វិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីធានាឱ្យមានភាពស្មើគ្នានៃអាពាហ៍ពិពាហ៍សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា។ (១១០.៤៧) | អ៊ីស្លង់ |
| វិសោធនកម្ម មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីទទួលបានភាពស្មើគ្នានៃការរៀបអាពាហ៍ពិពាហ៍ជាមួយនឹងការបន្តការយកចិត្តទុកដាក់ស្មើគ្នាចំពោះប្រជាជនដែលជា ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងបុគ្គលអន្តរភេទនៅគ្រប់តំបន់។ (១១០.៥២) | ហូឡង់ |
| វិសោធនកម្មមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាត្តិឱ្យដៃគូអ្នកស្រឡាញ់ភេទដូចគ្នាអាចរៀបអាពាហ៍ពិពាហ៍បាន។ (១១០.៥៥) | កាណាដា |
| **បង្កើតឱ្យមានច្បាប់និងគោលនយោបាយស្តីពីការប្រឆាំងនឹងការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នា** | |
| បង្កើតឱ្យមានច្បាប់ស្តីពី ការប្រឆាំងនឹងការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នា ដែលធានានិងហាមឃាត់នូវរាល់ទម្រង់នៃការរើសអើងទាំងអស់ រាប់បញ្ចូលការរើសអើងផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវយេនឌ័រ និងលក្ខណៈភេទ។ (១១០.៤៥) | អ៊ីស្លង់ |
| រៀបចំកិច្ចពិភាក្សាជាមួយអង្គការសង្គមស៊ីវិល ទៅលើគោលនយោបាយ និងច្បាប់ដែលទូលំទូលាយពី ការប្រឆាំងនឹងការរើសអើង និងអំពើហិង្សាលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ | ម៉ិចស៊ីកូ |

| | |
|---|---|
| ហើយជានាអំពី ការអនុវត្តនៅគ្រប់សាធារណជនទាំងមូល ជាពិសេសក្នុងវិស័យអប់រំ សុខភាព និងការងារ។ (១១០.៥០) | |
| បង្កើតឱ្យមានច្បាប់ថ្មី ដែលធានាបាននូវភាពស្មើគ្នានិងហាមឃាត់ចំពោះការរើសអើងស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងបុគ្គលអន្តរភេទ។ (១១០.៥២) | ស៊ុយអ៊ែត |
| រៀបចំវិធីសាស្ត្រប្រកបដោយប្រសិទ្ធិភាព ដោយរួមបញ្ចូលនូវការដាក់ទោសទណ្ឌ ចំពោះអំពើរើសអើងនិងអំពើហិង្សាផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។ (១១០.៥៣) | អ៊ុយរូហ្គាយ |
| ត្រឹមឆ្នាំ២០២៣ បង្កើតឱ្យមានច្បាប់ស្តីពីការប្រឆាំងនឹងការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នា ដែលធានានូវភាពស្មើគ្នា និងហាមឃាត់រាល់ទម្រង់នៃការរើសអើងទាំងអស់ រាប់បញ្ចូលការរើសអើងផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវយេនឌ័រ និងលក្ខណៈភេទ។ (១១០.៥៤) | អូស្ត្រាលី |
| **បង្កើតឱ្យមានច្បាប់ទទួលស្គាល់អត្តសញ្ញាណយេនឌ័ររបស់អ្នកប្តូរយេនឌ័រ** | |
| តាក់តែងច្បាប់ស្តីពី ការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ របស់អ្នកស្រលាញ់ភេទដូចគ្នា។ (១១០.៥៤) | អ៊ីស្លង់ |

### តើអ្វីជាយន្តការនៃពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកលតាមកាលកំណត់ (យូ.ភី.អ)?

- យន្តការ យូ.ភី.អ គឺជាយន្តការរបស់អង្គការសហប្រជាជាតិ ដែលរដ្ឋជាសមាជិកប្រកាន់ខ្ជាប់នូវកាតព្វកិច្ចសិទ្ធិមនុស្ស ផ្តល់អនុសាសន៍ និងជំរុញការលើកស្ទួយស្ថានភាពសិទ្ធិមនុស្ស។ ជាទូទៅ យូ.ភី.អ មានរយៈពេល ៥ឆ្នាំក្នុងមួយជុំ ។
- យូ.ភី.អ នៅជុំទី៣ ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជាបានទទួលយកនិងកត់សម្គាល់នូវអនុសាសន៍សរុបចំនួន ១៩៨ (ទទួលយកចំនួន ១៧៣ និងកត់សម្គាល់ចំនួន ២៥) ពីរដ្ឋជាសមាជិកចំនួន៧៣ប្រទេស ។
- ការទទួលយកអនុសាសន៍ យូ.ភី.អ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តក្នុងការអនុវត្តអនុសាសន៍មុន យូ.ភី.អ ជុំបន្ទាប់។

ព័ត៌មានបន្ថែមអំពីយូ.ភី.អប្រទេសកម្ពុជា៖
https://www.sithi.org/upr & https://www.ohchr.org/EN/HRBodies/UPR/Pages/KHindex.aspx